# ព្រះរាជក្រឹត្យ

នស/រកត/០១០៨/០៦៤

ស្តីពី

**វិសោធនកម្មមាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ នៃព្រះរាជាណាចក្រកម្ពុជា**

## យើង

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE

- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គនាថ្ងៃទី៤ ខែមករា ឆ្នាំ២០០៨។

## ត្រាស់បង្គាប់

**មាត្រា មួយ._**

មាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកែសម្រួលដូចតទៅ:

**មាត្រា ៤ ថ្មី._**

**ម.អ.ជ.** ត្រូវគ្រប់គ្រងដឹកនាំដោយក្រុមប្រឹក្សាភិបាល **ម.អ.ជ.**។

សមាសភាពក្រុមប្រឹក្សាភិបាល ម.អ.ជ. មានជាអាទិ៍:

១. រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាប្រធាន

២. រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប ជាអនុប្រធាន

៣. រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ០១រូប ជាអនុប្រធាន

៤. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ០១រូប ជាសមាជិក

៥. តំណាងក្រសួងមហាផ្ទៃ ០១រូប ជាសមាជិក

៦. តំណាងក្រសួងផែនការ ០១រូប ជាសមាជិក

៧. ប្រធាន ឬអនុប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា ០១រូប ជាសមាជិក

៨. តំណាងដៃគូអភិវឌ្ឍន៍ ០១រូប ជាសមាជិក

៩. តំណាងសមាគមធនាគារកម្ពុជា ០១រូប ជាសមាជិក

១០. តំណាងអ្នកមានអាជ្ញាប័ណ្ណ ផ្ញើសេវាកម្មអគ្គិសនី ដែលបានចូលរួមក្នុងគម្រោងអភិវឌ្ឍអគ្គិសនីជនបទ ០១រូប ជាសមាជិក

១១. តំណាងអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការអន្តរជាតិដែលបានចូលរួម ក្នុងគម្រោងអភិវឌ្ឍអគ្គិសនីជនបទ ០១រូប ជាសមាជិក

ROYAUME DU CAMBODGE

១២. តំណាងអ្នកប្រើប្រាស់អគ្គិសនីជនបទ ០១រូប ជាសមាជិក ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃ ម.អ.ជ. ត្រូវកំណត់ដោយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ដែលនឹងត្រូវរៀបចំ និង សម្រេចដោយក្រុមប្រឹក្សាភិបាល ម.អ.ជ. ។

សមាជិកក្រុមប្រឹក្សាភិបាល ម.អ.ជ. មានអាណត្តិរយៈពេល ៣(បី)ឆ្នាំ ហើយនៅពេលបញ្ចប់អាណត្តិ អាចត្រូវបានតែងតាំងសម្រាប់អាណត្តិបន្តទៀតបាន ។

**មាត្រា ពីរ.–** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា បី.–** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០០៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ**
**សូមឡាយព្រះហស្តលេខា**
**នាយករដ្ឋមន្ត្រី**

៣រណ.០៥០១.០៦៧

**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខៈ ៧៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**
**ស៊ុន ចិនកេន**